00865080

**ឯកសារដើម**
**ORIGINAL DOCUMENT/DOCUMENT ORIGINAL**
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 11 / 2012
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E163/5/4

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២

**ជូនចំពោះ:** គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី:** និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** **ការជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល**

នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីដាក់ផ្នែកអង្គច្បាប់ពាក់ព័ន្ធនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ឲ្យបានត្រឹមថ្ងៃសុក្រ ទី ២១ ខែ ធ្នូ ឆ្នាំ ២០១២។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា ទម្រង់បែបបទបន្ថែមនៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនឹងត្រូវកំណត់ក្នុងពេលមួយសមស្រប (ឯកសារលេខ E163/5 កថាខណ្ឌ ៤)។ នាពេលនេះ អង្គជំនុំជម្រះសូមណែនាំបន្ថែមពាក់ព័ន្ធនឹងភាសា ការកម្រិតចំនួនទំព័រ និងកាលបរិច្ឆេទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។

ក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើឡើងថា សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល គួរដាក់ជាភាសាបារាំង ឬ ភាសាអង់គ្លេសជាដំបូងសិន ហើយសេចក្តីសន្និដ្ឋានបកប្រែជាភាសាខ្មែរ នឹងត្រូវបានដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ពុំមានភាគីណាមួយបានជំទាស់ឡើយ ហើយអង្គជំនុំជម្រះសាលាដំបូង នាពេលនេះ សម្រេចឯកភាពលើទម្រង់បែបបទនេះតែម្តង។ នៅក្នុងចន្លោះពេលនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលជាភាសាអង់គ្លេស ឬ បារាំង និងការដាក់ជាភាសាខ្មែរនោះ អង្គជំនុំជម្រះនឹងពឹងផ្អែកលើ

សមត្ថភាពបុគ្គលិកផ្ទៃក្នុងរបស់ខ្លួនដែលចេះភាសាបរទេសទាំងនេះ។ ក៏ប៉ុន្តែ ភាគីទាំងឡាយត្រូវបានស្នើសុំឱ្យទាក់ទងឱ្យបានជិតស្និទ្ធជាមួយនឹងអង្គភាពបកប្រែភាសាដើម្បីធ្វើយ៉ាងណាអាចដាក់សេចក្តីសន្និដ្ឋានបញ្ចប់ ការពិភាក្សាដេញដោលជាភាសាខ្មែរឱ្យបានឆាប់ទៅតាមលទ្ធភាពជាក់ស្តែង ក្រោយពេលសេចក្តីសន្និដ្ឋាន បញ្ចប់ការពិភាក្សាដេញដោលជាភាសាអង់គ្លេស ឬ បារាំង បានដាក់រួចរាល់។

អង្គជំនុំជម្រះបានបញ្ជាក់នាពេលមុនរួចហើយថា សេចក្តីសន្និដ្ឋានទាំងឡាយស្តីពីអង្គច្បាប់ជាធរមានដែលនឹងត្រូវដាក់ឱ្យបានមុនថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ ត្រូវបានកម្រិតឱ្យដាក់ជាភាសាអង់គ្លេស ឬ បារាំង ត្រឹមចំនួន ២០ ទំព័រ ប៉ុណ្ណោះ និង ៤០ ទំព័រ ជាភាសាខ្មែរ។ លើសពីនេះ អង្គជំនុំជម្រះសូមបញ្ជាក់ការកម្រិតចំនួនទំព័រដូចខាងក្រោម (ដាច់ដោយឡែក និងបន្ថែមលើចំនួនទំព័រដែលបានអនុញ្ញាតរួចហើយនៅក្នុងផ្នែកស្តីពីអង្គច្បាប់ជាធរមាន)៖

១. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហព្រះរាជអាជ្ញា៖ ២០០ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំង និងចំនួនទំព័រជាភាសាខ្មែរតាមជាក់ស្តែង។

២. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខ (ដោយមិនរាប់បញ្ចូលសេចក្តីសន្និដ្ឋានស្តីពីសំណង)៖ ៨០ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំង និងចំនួនទំព័រជាភាសាខ្មែរតាមជាក់ស្តែង។

៣. សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលរបស់ក្រុមមេធាវីការពារក្តី៖ ១០០ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំង និងចំនួនទំព័រជាភាសាខ្មែរតាមជាក់ស្តែងសម្រាប់ជនជាប់ចោទនីមួយៗ។

ដោយពិចារណាលើលទ្ធភាពដែលបានផ្តល់ឱ្យភាគីទាក់ទិននឹងការកម្រិតចំនួនទំព័រ និងភាសាដែលត្រូវដាក់អង្គជំនុំជម្រះកំណត់ថា គ្រប់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលទាំងអស់ត្រូវដាក់ជាភាសាអង់គ្លេស ឬ បារាំង មិនឱ្យលើសពី ៣០ ថ្ងៃ បន្ទាប់ពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលផ្ទាល់មាត់បានបញ្ចប់ ដែលសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដោយផ្ទាល់មាត់នេះនឹងត្រូវធ្វើឡើងមួយសប្តាហ៍ក្រោយបញ្ចប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១។ សេចក្តីសន្និដ្ឋានតបនឹងពុំទទួលយកឡើយ។ កាលបរិច្ឆេទកំណត់សម្រាប់ការដាក់សេចក្តីសន្និដ្ឋានស្តីពីសំណងធ្វើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងប្រកាសជូនដំណឹងក្នុងពេលសមស្រប។ សេចក្តីសន្និដ្ឋានស្តីពីសំណង ត្រូវបានកម្រិតឱ្យធ្វើឡើងត្រឹមចំនួន ៦០ ទំព័រ ជាភាសាអង់គ្លេស ឬ បារាំង និងចំនួនទំព័រជាភាសាខ្មែរតាមជាក់ស្តែង។

ចំណុចចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដែលបានសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញលើកាលបរិច្ឆេទនៃការដាក់ផ្នែកអង្គច្បាប់ជាធរមាននៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល(ឯកសារ E163/5/2)។

ក្រុមមេធាវីការពារក្តីបានលើកឡើងថា ការតម្រូវឱ្យដាក់សេចក្តីសន្និដ្ឋានផ្នែកអង្គច្បាប់ជាមុនដូច្នេះ ពុំមានលក្ខណៈសមស្រប ដោយហេតុថាអង្គជំនុំជម្រះមិនមានបំណងដើម្បីចេញសេចក្តីសម្រេចភ្លាមៗលើបញ្ហានេះឡើយ ហើយវានឹងរារាំងក្រុមមេធាវីការពារក្តីក្នុងការធ្វើសេចក្តីសន្និដ្ឋានបន្ថែមទាក់ទិននឹងការកំណត់អង្គហេតុតាមផ្លូវច្បាប់ (ឯកសារ E163/5/2 កថាខណ្ឌ ៩ ដល់ ១៤)។ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់បំភ្លឺថា សេចក្តីសន្និដ្ឋានដែលតម្រូវឱ្យដាក់នៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ គួរលើកឡើងអំពីធាតុផ្សំនីត្យានុកូលនៃបទល្មើសទាំងអស់ និងទម្រង់នៃការទទួលខុសត្រូវ ដែលអាចយកមកអនុវត្តបាននៅក្នុងសំណុំរឿង ០០២/០១។ បញ្ហាអង្គច្បាប់ទាំងនេះ ត្រូវបានក្លាយជាកម្មវត្ថុនៃបណ្តឹងតវ៉ាជាច្រើនលើកច្រើនសាររួចមកហើយ រួមទាំងនៅក្នុងអំឡុងពេលនៃដំណាក់កាលមុនអង្គសេចក្តីផងដែរ ហើយទោះក្នុងករណីណាក៏ដោយ បញ្ហាអង្គច្បាប់ទាំងនេះមានលក្ខណៈដាច់ដោយឡែកពីការបង្ហាញភស្តុតាងលើអង្គហេតុនានា ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ភាគីពុំត្រូវបានហាមឃាត់មិនឱ្យលើកឡើងការកំណត់អង្គហេតុតាមផ្លូវច្បាប់ ឬការវិវឌ្ឍថ្មីៗលើច្បាប់ពាក់ព័ន្ធ ក្រោយ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១២ នោះទេ ប្រសិនបើខ្លួនចង់លើកឡើងនោះ។ អង្គជំនុំជម្រះបដិសេធសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលបានលើកឡើងថា ការកំណត់ចំនួនទំព័រចំពោះសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានកំណត់ឡើងលឿនពេក (ឯកសារលេខ E163/5/2 កថាខណ្ឌ ២១)។ ការអះអាងដែលក្រុមមេធាវីការពារក្តីលើកឡើងថា ចំនួនទំព័រអប្បបរមា ៣០០ ទំព័រ ដែលពួកគេត្រូវការសម្រាប់ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល គឺពុំស៊ីសង្វាក់គ្នាឡើយជាមួយនឹងសំណើសុំនាពេលមុនដែលបានលើកឡើងថា ពួកគេចាំបាច់ត្រូវការចំនួនទំព័រអប្បបរមាពី ១៥០ ទៅ ១៨០ ទំព័រប៉ុណ្ណោះ (ប្រតិចារឹក ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣)។